**ជំនួយស្មារតីដើម្បីយល់ដឹងអំពីគណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ (គ.ស.ប)**

**បាវចនា ៖ រួមគិត រួមធ្វើ រួមទទួលខុសត្រូវ**

**គោលដៅ ៖ មាតុភូមិមួយដែលពួកយើងរស់នៅដោយស្មើភាពគ្នាក្នុងភាពជាម្ចាស់**

ប្រែក្លាយយន្តការប្រាំបីចំណុចឲ្យទៅជាច្បាប់

សកម្មភាពប្រែក្លាយយន្តការប្រាំបីចំណុចឲ្យទៅជាច្បាប់ ៖ **ពន្យល់ ពន្យល់ និង ពន្យល់**

ឧឧឧ៙៙៙៙

- ដោយមើលឃើញថា ការរីករាលដាលនៃអំពើអយុត្តិធម៌កាន់តែកើនឡើង ពាក់ព័ន្ធទៅនឹងការបែងចែកភោគផលធនធានធម្មជាតិ ដែលដូនតាបានបន្សល់ទុកមក បានធ្វើឲ្យជីវភាពរស់នៅរបស់មនុស្សមួយក្តាប់តូចចេះតែធូរជាទៅៗ និងប្រជាពលរដ្ឋមួយចំនួនធំគ្មានឱកាសកែលម្អស្ថានភាពរស់នៅឲ្យបានប្រសើរសមជាពលរដ្ឋក្នុងទឹកដីសុវណ្ណភូមិ។
- ដោយមើលឃើញថា ភាពអយុត្តិធម៌ក្នុងប្រព័ន្ធតុលាការ បណ្តាលឲ្យមនុស្សល្អ/ត្រូវ ទទួលរងនូវការចាញ់ក្តីទាំងបំពាន និងច្បាស់ក្រឡែត ដោយអំណាចទឹកប្រាក់របស់អ្នកមានទ្រព្យសម្បត្តិ និងអ្នកមានអំណាច។
- ដោយមើលឃើញថា សីលធម៌សង្គមបានធ្លាក់ចុះយ៉ាងគំហុក ជាពិសេស ពាក់ព័ន្ធទៅនឹងសុចរិតភាពរបស់ពលរដ្ឋ និងការទទួលខុសត្រូវរបស់ខ្លួនក្នុងក្របខ័ណ្ឌបុគ្គលជាសមាជិកគ្រួសារ និងជាពលរដ្ឋរបស់ប្រទេសជាតិ
- ដោយមើលឃើញថា កម្ពុជាកំពុងតែស្ថិតនៅក្នុងការគម្រាមកំហែងយ៉ាងពិតប្រាកដពីសំណាក់ប្រទេសជិតខាងដែលនាំដល់ការបាត់ទឹកដី និងជាតិសាសន៍។
- ដោយយល់ឃើញថា បញ្ហាទាំងអស់ដូចបានរៀបរាប់ខាងលើនេះកើតចេញពីប្រព័ន្ធនៃការគ្រប់គ្រងប្រទេសដោយអំណាចប្រមូលផ្តុំទៅលើបុគ្គលតែម្នាក់ ឬមួយក្រុមតូច។
- ដោយយល់ឃើញថា ការដឹកនាំតាមប្រព័ន្ធអំណាចប្រមូលផ្តុំនៅតែបន្ត ពីមួយជំនាន់ទៅមួយជំនាន់ ដោយសារតែភាពអសកម្មរបស់ប្រជាពលរដ្ឋភាគច្រើនក្នុងការមិនចូលរួមក្នុងចលនានយោបាយ និងមួយចំនួនចូលរួមក្នុងចលនានយោបាយដោយគ្មានការយល់ដឹងច្បាស់លាស់។

គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យត្រូវបានបង្កើតឡើង ហើយទទួលស្គាល់ដោយសេចក្តីប្រកាសរបស់ក្រសួងមហាផ្ទៃ លេខ ៧៩១ ប្រ.ក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០០៦។

គ.ស.ប ត្រូវបានបង្កើតឡើង ដោយមានទស្សនៈវិស័យមុតស្រួចក្នុងការពន្យល់ប្រជាពលរដ្ឋឲ្យផ្លាស់ប្តូរ ផ្នត់គំនិតពីការចូលរួមក្នុងនយោបាយដោយការដង្ហែរតាមមេគណបក្សនយោបាយទាំងគ្មានការយល់ដឹង មកគាំទ្រទស្សនៈថ្មីនៃការធ្វើនយោបាយ ដោយការចូលរួមគិត រួមធ្វើ និងរួមទទួលខុសត្រូវ ចំពោះ សកម្មភាពនយោបាយ និងជោគវាសនាខ្លួន ដើម្បីឈានទៅសម្រេចគោលដៅនៃការបង្កើតសង្គម ប្រជាធិបតេយ្យ ដែលពលរដ្ឋកម្ពុជារស់នៅដោយស្មើភាពគ្នាក្នុងភាពជាម្ចាស់។

លក្ខណៈពិសេសដែលធ្វើឲ្យគសប ខុសពីគណបក្សនយោបាយដទៃទៀតនៅកម្ពុជា ដោយចំណុច បួនយ៉ាងខាងក្រោមនេះ ៖

- **គោលដៅរួម ៖** មាតុភូមិមួយដែលពួកយើងរស់នៅដោយស្មើភាពគ្នាក្នុងភាពជាម្ចាស់
- **ចំណុចចាប់ផ្តើម ៖** ការពន្យល់ប្រជាពលរដ្ឋដោយឈរលើគោលធំៗបី ដើម្បីឲ្យមានការចូលរួម ជាកម្លាំងសរុបពីសំណាក់ពលរដ្ឋដែលជាម្ចាស់ប្រទេស
- **ឥរិយាបថនយោបាយ ៖** សុចរិតភាពជាបាតគ្រឹះ ក្នុងទង្វើរបស់ខ្លួនទាំងអស់
- **ធនធានមនុស្ស ៖** ជាអ្នកមានគុណសម្បត្តិបេះដូងជួយសង្គ្រោះផង និងជាអ្នកមានគុណ សម្បត្តិខួរក្បាលក្នុងការត្រិះរិះពិចារណាផង។

ដើម្បីឲ្យមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋ ដែលជាមធ្យោបាយឈានទៅសម្រេចគោលដៅរបស់ ខ្លួន គសប បានចាត់ទុកសកម្មភាពពន្យល់ប្រជាពលរដ្ឋ ជាអាទិភាពចម្បងក្នុងសកម្មភាពរបស់ខ្លួន។ ការពន្យល់ត្រូវបានធ្វើឡើងដោយផ្អែកលើគោលធំៗចំនួនបី ៖

- **គោលទីមួយ ៖** នាំទៅដល់ការផ្លាស់ប្តូរប្រព័ន្ធនៃការគ្រប់គ្រងកម្ពុជា និងការកែប្រែសង្គមកម្ពុជា ទាំងមូលនោះ។ ពន្យល់ប្រជាពលរដ្ឋបអំពីលទ្ធិប្រជាធិបតេយ្យ ដំណើរការបង្កើតសង្គម ប្រជាធិបតេយ្យ និងទម្រង់នៃការចូលរួមរបស់ពលរដ្ឋ តាមលំនាំដែលបណ្តាប្រទេសលោកខាង លិចកំពុងអនុវត្តន៍។ គសប កំពុងតែពន្យល់ប្រជាពលរដ្ឋឲ្យមានការចូលរួម តាមគតិរបស់ ប្រធានាធិបតីសហរដ្ឋអាមេរិក Abraham Lincoln ដែលលោកមានប្រសាសន៍ថា "រដ្ឋាភិបាល ប្រជាធិបតេយ្យគឺជារដ្ឋាភិបាលរបស់ប្រជាពលរដ្ឋ បង្កើតឡើងដោយប្រជាជន និងដើម្បី បម្រើប្រជាជន"។ ពាក់ព័ន្ធនឹងចំណុចនេះ គសបពន្យល់ប្រជាពលរដ្ឋឲ្យពួកគាត់ដឹងថាតើ ពួកគាត់មានសិទ្ធិ និងកាតព្វកិច្ចអ្វីខ្លះក្នុងភាពជាម្ចាស់ប្រទេស និងអំណាច ដែលពលរដ្ឋត្រូវមានដើម្បីប្រើប្រាស់សិទ្ធិដែលមានចែងនៅក្នុងច្បាប់ ដោយគ្មានការភ័យខ្លាច។

- **គោលទីពី ៖** ពន្យល់អំពីមេរៀនត្រាស់ដឹងរបស់ព្រះពុទ្ធ ដែលទាក់ទងនឹងជីវិត ដើម្បីឲ្យពលរដ្ឋមានការយល់ដឹងអំពីអំពើបុណ្យ/ល្អ និងអំពើបាប/អាក្រក់ និងមានសទ្ធាជ្រះថ្លា ចូលរួមក្នុងសកម្មភាពរបស់គសប ដែលជាសកម្មភាពចាគៈប្រាស់ចាកភាពអាត្មានិយម។ នេះគឺជាទង្វើតាមគន្លងរបស់ព្រះសម្មាសម្ពុទ្ធនៃយើង ដែលព្រះអង្គបានលះបង់អ្វីៗសព្វបែបយ៉ាង និងគ្រប់ៗជាតិដើម្បីតែប្រយោជន៍ និងសេចក្ដីសុខរបស់អ្នកដទៃតែប៉ុណ្ណោះ។

- **គោលទីបី ៖** ពន្យល់ ដោយប្រើព្រះធម៌ជាមូលដ្ឋានគ្រឹះដើម្បីផ្លាស់ប្ដូរផ្នត់គំនិតរបស់ប្រជាពលរដ្ឋអំពីសីលធម៌សង្គម និងប្រែក្លាយខ្លួនទៅជាពលរដ្ឋល្អ និងទទួលខុសត្រូវ ទាំងក្នុងក្របខ័ណ្ឌបុគ្គល គ្រួសារ សហគមន៍ និងប្រទេសជាតិ។ ការដឹងថាអ្វីជាអំពើល្អ និងអ្វីជាអំពើអាក្រក់ នឹងជួយលើកទឹកចិត្តប្រជាពលរដ្ឋឲ្យចូលរួមក្នុងសកម្មភាពគសប ដោយមិនសំដៅចង់បានប្រយោជន៍ និងសេចក្ដីសុខផ្ទាល់ខ្លួន ក្រៅពីការជួយប្រទេសជាតិ ដោយបេះដូងសង្គ្រោះនោះទេ។

នៅពេលប្រជាពលរដ្ឋមានការយល់ដឹងច្បាស់លាស់លើគោលធំៗទាំងបីនេះរួចហើយ គសប នឹងគៀងគរកម្លាំងប្រជាពលរដ្ឋទៅបំបែកអំណាចប្រមូលផ្ដុំនៃការគ្រប់គ្រង ដែលជាប្រភពនៃបញ្ហាសង្គមសព្វបែបយ៉ាងនាពេលបច្ចុប្បន្ន តាមរយៈការបោះឆ្នោតគាំទ្រយន្តការប្រាំបីចំណុចរបស់របស់គសប ដោយការយល់ដឹង។

យន្តការប្រាំបីចំណុចរួមមាន ៖

១. កំណត់អាណត្តិនាយករដ្ឋមន្ត្រីត្រឹមពីរអាណត្តិ
២. មិនអនុញ្ញាតឲ្យនាយករដ្ឋមន្ត្រីបង្កើតក្រុមអង្គរក្សដោយខ្លួនឯង
៣. នាយករដ្ឋមន្ត្រីរស់នៅក្នុងនិវេសនដ្ឋានដែលផ្ដល់ដោយរដ្ឋ
៤. បង្កើតតុលាការរដ្ឋបាល
៥. ការផ្ដល់សេចក្ដីសម្រេចទុកចិត្តដោយសភា ដើម្បីជ្រើសតាំងឧត្តមសេនីយ៍យោធា និងនគរបាល
៦. អព្យាក្រឹតមន្ត្រីរាជការ
៧. ការបោះឆ្នោតជ្រើសរើស និងការបោះឆ្នោតដកតំណាងគ្រប់លំដាប់ថ្នាក់- ឃុំ/សង្កាត់ ស្រុក/ខណ្ឌ ខេត្ត/រាជធានី - ដោយប្រជាពលរដ្ឋផ្ទាល់

៨. ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រតាមប្រព័ន្ធឯកត្តនាម

ចូលរួមជាមួយគសបទាំងកម្លាំងកាយ ចំណេះដឹង និងថវិកា ដើម្បីប្រែក្លាយយន្តការប្រាំបីចំណុចឲ្យទៅជាច្បាប់ដើម្បីផ្លាស់ប្តូរការដឹកនាំប្រទេសជាតិពីប្រព័ន្ធអំណាចប្រមូលផ្តុំ (ប្រជាធិបតេយ្យ) ទៅជាប្រព័ន្ធដឹកនាំដែលអំណាចមិនប្រមូលផ្តុំ គឺជាការចូលរួមក្នុងសកម្មភាពនៃការបង្កើតប្រវត្តិសាស្ត្រថ្មីសម្រាប់កម្ពុជា ដែលកូនចៅជំនាន់ក្រោយៗអាចទទួលបានផលប្រយោជន៍យ៉ាងស្មើភាពគ្នាក្នុងភាពជាម្ចាស់នៅលើទឹកដីសុវណ្ណភូមិយើងនេះ។

**ទំនាក់ទំនង ÷**


អាសយដ្ឋាន ៖ ផ្ទះលេខ១០៨ B២ផ្លូវ៣១៥សង្កាត់បឹងកក់២ខណ្ឌទួលគោករាជធានីភ្នំពេញ

ទូរស័ព្ទ:០១២៣៦៣៦២២

**អ៊ីមែល ៖** info@camldp.org / camldp3@gmail.com

**គេហទំព័រ ៖** www.camldp.org

**វិទ្យុ ៖** FM105 ម៉ោង ២-៣ រសៀល(ភ្នំពេញ)

**សួស សុភក្តិ**